**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០០៦ ទសចណ

ថ្ងៃ ចន្ទ ៩រោច ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៨

**សារាចរណែនាំ**

**ស្តីពី**

**ការរៀបចំមណ្ឌលព័ត៌មាន និងបញ្ជរព័ត៌មានទេសចរណ៍ ដើម្បីត្រៀមទទួលស្វាគមន៍ភ្ញៀវទេសចរ ពិសេសក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០១៨**

ដើម្បីចូលរួមអបអរសាទរ **ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០១៨** ខាងមុខ ពិសេសដើម្បីចូលរួមជំរុញចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** ដើម្បីធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងកក់ក្តៅ "Cambodia, Kingdom of Wonder- Feel the Warmth" ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដល់មន្ទីរទេសចរណ៍រាជធានី-ខេត្ត ដូចខាងក្រោម៖

ទី១. ត្រូវធ្វើការរៀបចំតុបតែងលម្អមណ្ឌលព័ត៌មាន និងបញ្ជរព័ត៌មានទេសចរណ៍ដែលមាននៅក្នុងខេត្តរបស់ខ្លួនឱ្យបានសមស្រប និងមានភាពទាក់ទាញដើម្បីត្រៀមទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមកទស្សនាតាមគោលដៅទេសចរណ៍នៅក្នុងខេត្តរបស់ខ្លួន

ទី២. ត្រូវចាត់តាំងមន្ត្រីប្រចាំការនៅតាមមណ្ឌលព័ត៌មាន និងបញ្ជរព័ត៌មានទេសចរណ៍នីមួយៗដែលអាចផ្តល់ព័ត៌មានពីតំបន់ទេសចរណ៍ ពិសេសព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗដូចជាព្រឹត្តិការណ៍សង្ក្រាន្តឆ្នាំថ្មីដែលមានរៀបចំឡើងនៅក្នុងខេត្តរបស់ខ្លួនជូនដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ

ទី៣. ត្រូវរៀបចំឯកសារ ទិត្ថបណ្ណផ្សព្វផ្សាយ ផែនទីគោលដៅទេសចរណ៍ក្នុងខេត្ត បញ្ជីសេវាកម្មស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាន និងការីទេសចរណ៍ ឱ្យបានគ្រប់គ្រាន់សម្រាប់ជូនដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ

ទី៤. ត្រូវរៀបចំបរិស្ថានជុំវិញឱ្យមានសណ្តាប់ធ្នាប់រៀបរយប្រកបដោយភាពបៃតង និងមានកន្លែងសម្រាប់ភ្ញៀវទេសចរឈប់សម្រាក ។

E-mail: admin@mot.gov.kh Website: www.tourismcambodia.org

ទទួលបានសារាចរណែនាំនេះ គ្រប់មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវអនុវត្តតាមខ្លឹមសារខាងលើ ឱ្យបានត្រឹមត្រូវ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រដ្ឋមន្ត្រី

ថោង ខុន

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលារាជធានី-ខេត្ត
  "ដើម្បីជ្រាប"
- គ្រប់មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ